# សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាព

Health Plan of San Joaquin | Mountain Valley Health Plan

សេចក្តីជូនដំណឹងនេះពិពណ៌នាអំពីរបៀបដែលយើងខ្ញុំអាចប្រើ និងបង្ហាញព័ត៌មានវេជ្ជសាស្ត្រ និងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។ សេចក្តីជូនដំណឹងនេះរួមបញ្ចូលព័ត៌មានអំពីពូជសាសន៍/ជនជាតិ ភាសា អត្តសញ្ញាណយេនឌ័រ និងទំនោរផ្លូវភេទរបស់អ្នក។ សេចក្តីជូនដំណឹងនេះក៏ប្រាប់អ្នកពីរបៀបដែលអ្នកអាចចូលមើលព័ត៌មាននេះផងដែរ។ **សូមអានព័ត៌មាននេះដោយយកចិត្តទុកដាក់។**

## សិទ្ធិរបស់អ្នក

**នៅពេលនិយាយអំពីព័ត៌មានសុខភាពរបស់អ្នក អ្នកមានសិទ្ធិ។** ផ្នែកនេះពន្យល់អំពីសិទ្ធិរបស់អ្នក និងទំនួលខុសត្រូវរបស់យើងខ្ញុំក្នុងការជួយអ្នក។

| | |
|---|---|
| **ទទួលបានច្បាប់ចម្លងនៃកំណត់ត្រាសុខភាព និងកំណត់ត្រាទាមទារសំណងរបស់អ្នក** | • អ្នកអាចស្នើសុំមើល ឬទទួលបានច្បាប់ចម្លងនៃកំណត់ត្រារបស់អ្នក និងព័ត៌មានសុខភាពផ្សេងទៀតដែលយើងខ្ញុំមានអំពីអ្នក។ សួរយើងខ្ញុំពីរបៀបធ្វើដូច្នេះ។<br>• យើងខ្ញុំនឹងផ្តល់ច្បាប់ចម្លង ឬសេចក្តីសង្ខេបអំពីកំណត់ត្រាសុខភាព និងកំណត់ត្រាទាមទារសំណងរបស់អ្នកជាធម្មតាក្នុងរយៈពេល 30 ថ្ងៃបន្ទាប់ពីការស្នើសុំរបស់អ្នក។ យើងខ្ញុំអាចគិតថ្លៃសេវាទៅតាមតម្លៃ។ |
| **ស្នើសុំឱ្យយើងខ្ញុំកែតម្រូវកំណត់ត្រាសុខភាព និងកំណត់ត្រាទាមទារសំណង** | • អ្នកអាចស្នើសុំឱ្យយើងខ្ញុំកែតម្រូវកំណត់ត្រាព័ត៌មានសុខភាព និងការទាមទារសំណងរបស់អ្នក ប្រសិនបើអ្នកគិតថាព័ត៌មាននោះមានភាពមិនត្រឹមត្រូវ ឬមិនពេញលេញ ។<br>• សួរយើងខ្ញុំពីរបៀបធ្វើដូច្នេះ។ យើងខ្ញុំអាចនិយាយថា “មិនព្រម” ចំពោះសំណើរបស់អ្នក ប៉ុន្តែយើងខ្ញុំនឹងប្រាប់អ្នកពីមូលហេតុជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 60 ថ្ងៃ។ |
| **ស្នើសុំការទំនាក់ទំនងបែបសម្ងាត់** | • អ្នកអាចស្នើសុំឱ្យយើងខ្ញុំទាក់ទងអ្នកតាមវិធីជាក់លាក់មួយ (ឧទាហរណ៍ ទូរសព្ទនៅផ្ទះ ឬទូរសព្ទនៅការិយាល័យ) ឬផ្ញើសំបុត្រទៅអាសយដ្ឋានផ្សេង។<br>• យើងខ្ញុំនឹងពិចារណាលើសំណើសមហេតុផលទាំងអស់។ យើងខ្ញុំនឹងនិយាយថា "ព្រម" ប្រសិនបើអ្នកប្រាប់យើងខ្ញុំថាអ្នកនឹងស្ថិតក្នុងគ្រោះថ្នាក់ ប្រសិនបើយើងខ្ញុំបដិសេធសំណើរបស់អ្នក។<br>• យើងខ្ញុំនឹងដំណើរការ ដើម្បីផ្លាស់ប្តូរការទំនាក់ទំនងសម្ងាត់ទាំងអស់ តាមការស្នើសុំ របស់អ្នក ។ ចំណុចនេះអាចកើតឡើងក្នុងរយៈពេល 7 ថ្ងៃតាម ប្រតិទិន គិតចាប់ពីពេលដែលយើងខ្ញុំទទួលបានសំណើជាលាយលក្ខណ៍អក្សររបស់អ្នក ។ ក្នុងរយៈពេល 14 ថ្ងៃតាមប្រតិទិន គិតចាប់ពីថ្ងៃទទួលបានសំណើរបស់អ្នកតាមរយៈសំបុត្រថ្នាក់លេខមួយ ។ យើងខ្ញុំនឹងផ្ញើលិខិត ដើម្បីប្រាប់អ្នកឱ្យដឹងថាយើងខ្ញុំបានទទួលសំណើរបស់អ្នកហើយ ។<br>• ប្រសិនបើអ្នកជាមនុស្សចាស់ដែលមានពិការភាពជាប់ខ្លួន (SPD) ហើយអសមត្ថភាពរាងកាយ ឬខួរក្បាល អ្នកមិនចាំបាច់បំពេញទម្រង់បែបបទផ្តល់ការអនុញ្ញាត ឡើយ ។ |

| | |
|---|---|
| **សុំឱ្យយើងកំណត់អ្វីដែលយើងចែករំលែកអំពីអ្នក** | • អ្នកអាចស្នើសុំឱ្យយើងខ្ញុំ **កុំ** ប្រើ ឬចែករំលែកព័ត៌មានសុខភាពជាក់លាក់សម្រាប់ការព្យាបាល ការទូទាត់ប្រាក់ ឬប្រតិបត្តិការរបស់យើង។<br>• មិនមានច្បាប់ ដែលតម្រូវឱ្យយើងខ្ញុំ ត្រូវតែយល់ព្រមតាមសំណើរបស់អ្នកទាំងអស់ឡើយ ហើយយើងខ្ញុំអាច "បដិសេធ" ប្រសិនបើសំណើនោះអាចប៉ះពាល់ដល់ការថែទាំរបស់អ្នក ។ |
| **ទទួលបានបញ្ជីឈ្មោះអ្នកដែលយើងខ្ញុំចែករំលែកព័ត៌មានរបស់អ្នកជាមួយ** | • អ្នកអាចស្នើសុំបញ្ជី (គណនេយ្យ) នៃពេលវេលាដែលយើងបានចែករំលែកព័ត៌មានសុខភាពរបស់អ្នក ។ នេះនឹងរួមបញ្ចូលទាំងពេលវេលាក្នុងប្រាំមួយឆ្នាំមុនកាលបរិច្ឆេទដែលអ្នកបានសួរថាតើយើងខ្ញុំបានចែករំលែកព័ត៌មាននេះជាមួយអ្នកណា និងមូលហេតុនៃការចែករំលែក។<br>• យើងខ្ញុំនឹងរួមបញ្ចូលការលាតត្រដាងទាំងអស់នៃព័ត៌មាននេះ លើកលែងតែសម្រាប់ការព្យាបាល ការទូទាត់ និងប្រតិបត្តិការថែទាំសុខភាព និងការបង្ហាញមួយចំនួនផ្សេងទៀត (ដូចជាអ្វីដែលអ្នកបានស្នើឱ្យយើងធ្វើ)។ យើងខ្ញុំនឹងផ្តល់ជូនគណនេយ្យមួយរយៈពេលមួយឆ្នាំដោយឥតគិតថ្លៃ។ យើងខ្ញុំនឹងគិតថ្លៃសេវាតាមតម្លៃសមរម្យពីអ្នក ប្រសិនបើអ្នកស្នើសុំគណនេយ្យមួយទៀតក្នុងរយៈពេល 12 ខែ។ |
| **ទទួលបានច្បាប់ចម្លងនៃសេចក្តីជូនដំណឹងអំពីឯកជនភាព** | • អ្នកអាចស្នើសុំសំណៅជាក្រដាស នៃសេចក្តីជូនដំណឹងនេះ នៅពេលណាក៏បាន ។ ទោះបីជាអ្នកបានយល់ព្រមទទួលយកសេចក្តីជូនដំណឹងនេះតាមប្រព័ន្ធអេឡិចត្រូនិកក៏ដោយ យើងខ្ញុំនឹងនៅតែផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងក្រដាសភ្លាមៗ។ |
| **ជ្រើសរើសនរណាម្នាក់ដើម្បីធ្វើការជំនួសអ្នក** | • ប្រសិនបើអ្នកបានផ្តល់ឱ្យនរណាម្នាក់នូវលិខិតផ្ទេរសិទ្ធិសម្រេចចិត្តជំនួស ឬប្រសិនបើនរណាម្នាក់ជាអាណាព្យាបាលស្របច្បាប់របស់អ្នក បុគ្គលនោះអាចប្រើប្រាស់សិទ្ធិរបស់អ្នក និងធ្វើការជ្រើសរើសអំពីព័ត៌មានសុខភាពរបស់អ្នក។<br>• យើងខ្ញុំនឹងធ្វើឲ្យប្រាកដថា បុគ្គលនោះមានសិទ្ធិអំណាចនេះ ហើយអាចធ្វើការជំនួសអ្នកបាន មុនពេលយើងខ្ញុំចាត់វិធានការអ្វីមួយ។ |
| **សូមដាក់បណ្តឹង ប្រសិនបើអ្នកយល់ថា សិទ្ធិរបស់អ្នកត្រូវបានគេរំលោភបំពាន** | • អ្នកអាចដាក់បណ្តឹងបាន ប្រសិនបើអ្នកយល់ថា យើងខ្ញុំបានរំលោភសិទ្ធិរបស់អ្នក។ សូមទាក់ទងមកយើងខ្ញុំ ដោយប្រើព័ត៌មាននៅលើទំព័រខាងក្រោយ។<br>• អ្នកអាចដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យក្រសួងសុខាភិបាល និងសេវាមនុស្សសហរដ្ឋអាមេរិក (U.S. Department of Health and Human Services Office) D.C. 20201 ដោយហៅទៅលេខ **1-877-696-6755** ឬចូលទៅកាន់គេហទំព័រ www.hhs.gov/ocr/privacy/hipaa/complaints។<br>• យើងខ្ញុំនឹងមិនសងសឹកអ្នកចំពោះការដាក់ពាក្យបណ្តឹងនោះទេ។ |

| | |
|---|---|
| **ស្នើសុំឲ្យគេផ្ញើព័ត៌មានសុខភាពរបស់អ្នកទៅកាន់កម្មវិធីតាមជម្រើសរបស់អ្នក** | • ច្បាប់អន្តរប្រតិបត្តិការតម្រូវឱ្យយើងខ្ញុំផ្តល់ទិន្នន័យថែទាំសុខភាពជាក់លាក់មួយចំនួនរហូតដល់ប្រាំឆ្នាំ នៅពេលអ្នកស្នើសុំវាដោយផ្ទាល់មកយើងខ្ញុំ ឬតាមរយៈកម្មវិធីរបស់ភាគីទីបី។<br>• នៅពេលអ្នកស្នើសុំវាតាមរយៈកម្មវិធីភាគីទីបី Health Plan រក្សាសិទ្ធិក្នុងការយលព្រមនឹងកម្មវិធីភាគីទីបីដោយផ្អែកលើការវិភាគសុវត្ថិភាព។<br>• អ្នកអាចធ្វើសំណើនេះដោយផ្ទាល់ជាមួយយើងខ្ញុំ ដោយចូលទៅកាន់ទម្រង់បែបបទស្នើសុំចូលមើលព័ត៌មានសុខភាពតាមអនឡាញ (www.hpsj-mvhp.org) ស្នើសុំតាមទូរសព្ទជាមួយអ្នកតំណាងសេវាបម្រើអតិថិជន ឬមកការិយាល័យយើងខ្ញុំដោយផ្ទាល់។<br>• អ្នកត្រូវតែបំពេញទម្រង់បែបបទទាំងមូល ហើយផ្ញើតាមប្រៃសណីយ៍ ឬយកវាមកកាន់ការិយាល័យរបស់ Health Plan ដែលមានទីតាំងនៅ 7751 South Manthey Road, French Camp, CA 95231។ អ្នកក៏អាចផ្ញើទម្រង់បែបបទនេះតាមទូរសារទៅលេខ៖ **1-209-461-2550** ឬផ្ញើទៅ Health Plan តាមរយៈអ៊ីមែលសុវត្ថិភាពផងដែរ។<br>• យើងខ្ញុំមិនទទួលខុសត្រូវលើកម្មវិធីភាគីទីបី ដែលអ្នកជ្រើសរើសប្រើឡើយ។ យើងខ្ញុំមិនទទួលខុសត្រូវចំពោះទិន្នន័យរបស់អ្នក នៅពេលដែលផ្ទេរទៅឲ្យអ្នកតាមរយៈកម្មវិធីភាគីទីបីឡើយ។ |

# ជម្រើសរបស់អ្នក

សម្រាប់ព័ត៌មានសុខភាពជាក់លាក់មួយចំនួន អ្នកអាចប្រាប់យើងខ្ញុំនូវជម្រើសរបស់អ្នកអំពីអ្វីដែលយើងខ្ញុំចែករំលែកបាន។ ប្រសិនបើអ្នកមានវិធីចែករំលែកព័ត៌មានរបស់អ្នក ដែលអ្នកចូលចិត្ត ចំពោះការចែករំលែកព័ត៌មាន ក្នុងស្ថានភាពដែលបានពិពណ៌នាខាងក្រោម សូមនិយាយជាមួយពួកយើង ។ សូមប្រាប់យើងខ្ញុំពីអ្វីដែលអ្នកចង់ឱ្យយើងខ្ញុំធ្វើ ហើយយើងខ្ញុំនឹងធ្វើតាមការណែនាំរបស់អ្នក។

**ក្នុងករណីទាំងនេះ អ្នកមានទាំងសិទ្ធិ និងជម្រើសក្នុងការប្រាប់យើងឱ្យ៖**

- ចែករំលែកព័ត៌មានជាមួយក្រុមគ្រួសារ មិត្តភក្តិជិតស្និទ្ធរបស់អ្នក ឬអ្នកផ្សេងទៀតដែលពាក់ព័ន្ធនឹងការទូទាត់ប្រាក់សម្រាប់ការថែទាំរបស់អ្នក
- ចែករំលែកព័ត៌មានក្នុងស្ថានភាពសង្គ្រោះគ្រោះមហន្តរាយ។

ប្រសិនបើអ្នកមិនអាចប្រាប់យើងខ្ញុំពីចំណូលចិត្តរបស់អ្នកបាន ឧទាហរណ៍ ប្រសិនបើអ្នកសន្លប់ នោះយើងអាចបន្តចែករំលែកព័ត៌មានរបស់អ្នក ប្រសិនបើយើងខ្ញុំជឿថាវាជាឧត្តមប្រយោជន៍របស់អ្នក។ យើងខ្ញុំក៏អាចចែករំលែកព័ត៌មានរបស់អ្នក នៅពេលចាំបាច់ ដើម្បីកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរ និងការគំរាមកំហែងដែលជិតកើតឡើងចំពោះសុខភាព ឬសុវត្ថិភាពរបស់អ្នកផងដែរ។

**ក្នុងករណីទាំងនេះ យើងខ្ញុំនឹងមិនចែករំលែកព័ត៌មានរបស់អ្នកឡើយ បើអ្នកមិនផ្តល់ការអនុញ្ញាតជាលាយលក្ខណ៍អក្សរសម្រាប់ចំណុចដូចខាងក្រោម៖**

- គោលបំណងធ្វើទីផ្សារ
- ការលក់ព័ត៌មានរបស់អ្នក

**ដូចគ្នានេះដែរ យើងខ្ញុំនឹងមិនប្រើព័ត៌មានរបស់អ្នកតាមវិធីដូចខាងក្រោម៖**

- ប្រើប្រាស់ព័ត៌មានជាតិសាសន៍/ជនជាតិ ភាសា អត្តសញ្ញាណយេនឌ័រ ឬនិន្នាការផ្លូវភេទដើម្បីធ្វើសេចក្តីសម្រេចលើការធានា ការបដិសេធការធានារ៉ាប់រង ឬតម្រូវឱ្យអ្នកបោះបង់សិទ្ធិរបស់អ្នកក្នុងការចុះឈ្មោះ ឬត្រូវបានធានារ៉ាប់រងក្រោម Health Plan។
- បញ្ចេញព័ត៌មានវេជ្ជសាស្ត្រ ឬព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកអំពីសេវារំលូតកូន ប្រសិនបើសំណើនេះចេញមកពីរដ្ឋមួយផ្សេងទៀត ទោះបីវាជាដីកាកោះហៅក៏ដោយ។ អ្នកត្រូវបានការពារដោយច្បាប់ស្តីពីឯកជនភាពនៃការបន្តពូជរបស់រដ្ឋ California (California Reproductive Privacy Act) ។
- ចេញផ្សាយព័ត៌មានវេជ្ជសាស្ត្រ ឬផ្ទាល់ខ្លួន សម្រាប់កុមារដែលទទួលការថែទាំសុខភាពដែលបញ្ជាក់ពីយេនឌ័រ ឬការថែទាំសុខភាពផ្លូវចិត្ត ដើម្បីឆ្លើយតបទៅនឹងបណ្តឹងរដ្ឋប្បវេណី ដីកាពីបរទេស ឬក្រៅចំណាត់ការរបស់រដ្ឋ ។ បង្ហាញព័ត៌មានអំពីការព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន (SUD) ដល់ផ្នែកនីតិវិធីរដ្ឋប្បវេណី ព្រហ្មទណ្ឌ រដ្ឋបាល ឬច្បាប់ប្រឆាំងនឹងសមាជិក ដោយគ្មានការយល់ព្រមពីសមាជិក ឬដីការបស់តុលាការ។
- ចែករំលែកព័ត៌មានរបស់អ្នកអំពីសេវាកម្មដែលទាក់ទងនឹងសុខភាពផ្លូវភេទ និងការបន្តពូជ ការឆ្លងមេរោគ និងជំងឺផ្លូវភេទ និងអំពើហិង្សារបស់ដៃគូជិតស្និទ្ធ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក លើកលែងតែសម្រាប់គោលបំណងការព្យាបាល ការទូទាត់ចំណាយ និងកិច្ចប្រតិបត្តិការរបស់យើងខ្ញុំ ។

# ការប្រើប្រាស់ និងការបង្ហាញព័ត៌មានដោយយើងខ្ញុំ

**តើជាធម្មតាយើងប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកដោយរបៀបណា?**

ជាធម្មតា យើងខ្ញុំប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកតាមវិធីដូចខាងក្រោម។

| | | |
|---|---|---|
| **ជួយគ្រប់គ្រងការព្យាបាលថែទាំសុខភាពដែលអ្នកទទួលបាន** | • យើងខ្ញុំអាចប្រើប្រាស់ព័ត៌មានសុខភាពរបស់អ្នក និងចែករំលែកព័ត៌មាននេះ ជាមួយអ្នកជំនាញដែលកំពុងព្យាបាលអ្នក។ | ***ឧទាហរណ៍៖*** *វេជ្ជបណ្ឌិតផ្ញើមកយើងនូវព័ត៌មានអំពីការធ្វើរោគវិនិច្ឆ័យ និងគម្រោងព្យាបាលរបស់អ្នក ដូច្នេះយើងអាចរៀបចំសេវាកម្មបន្ថែមបាន។* |
| **ដំណើរការស្ថាប័នរបស់យើង** | • យើងអាចប្រើប្រាស់ និងបញ្ចេញព័ត៌មានរបស់អ្នក ដើម្បីដំណើរការស្ថាប័នរបស់យើង ហើយទាក់ទងអ្នកនៅពេលចាំបាច់។<br>• យើងខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានហ្សែនរបស់អ្នក ដើម្បីសម្រេចថាតើយើងខ្ញុំនឹងផ្តល់ឱ្យអ្នកនូវការធានារ៉ាប់រង និងតម្លៃនៃការធានារ៉ាប់រងដែរឬទេ។ ចំណុចនេះមិនអនុវត្តចំពោះគម្រោងថែទាំរយៈពេលវែងឡើយ។ | ***ឧទាហរណ៍៖*** *យើងប្រើប្រាស់ព័ត៌មានសុខភាពអំពីអ្នក ដើម្បីអភិវឌ្ឍសេវាកម្មកាន់តែប្រសើរសម្រាប់អ្នក។* |
| **បង់ថ្លៃសេវាសុខភាពរបស់អ្នក** | • យើងខ្ញុំអាចប្រើប្រាស់ និងបង្ហាញព័ត៌មានសុខភាពរបស់អ្នក នៅពេលដែលយើងខ្ញុំបង់ថ្លៃសេវាសុខភាពរបស់អ្នក។ | ***ឧទាហរណ៍៖*** *យើងចែករំលែកព័ត៌មានអំពីអ្នកជាមួយនឹងគម្រោងសុខភាពធ្មេញរបស់អ្នក ដើម្បីសម្របសម្រួលការទូទាត់សម្រាប់ការងារសុខភាពធ្មេញរបស់អ្នក។* |
| **គ្រប់គ្រងគម្រោងរបស់អ្នក** | • យើងខ្ញុំអាចបង្ហាញព័ត៌មានសុខភាពរបស់អ្នកទៅដល់អ្នកឧបត្ថម្ភគម្រោងសុខភាពរបស់អ្នកសម្រាប់ការគ្រប់គ្រងគម្រោងថែទាំ។ | ***ឧទាហរណ៍៖*** *ក្រុមហ៊ុនរបស់អ្នកចុះកិច្ចសន្យាជាមួយយើងខ្ញុំដើម្បីផ្តល់គម្រោងសុខភាព ហើយយើងខ្ញុំផ្តល់ឱ្យក្រុមហ៊ុនរបស់អ្នកនូវស្ថិតិជាក់លាក់ដើម្បីពន្យល់អំពីថ្លៃបុព្វលាភរ៉ាប់រងដែលយើងខ្ញុំគិតថ្លៃ។* |

## តើយើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកតាមរបៀបផ្សេងទៀត ដោយរបៀបណា?

យើងត្រូវបានអនុញ្ញាត ឬតម្រូវឱ្យចែករំលែកព័ត៌មានរបស់អ្នកតាមវិធីផ្សេងទៀត ។ ជាធម្មតា យើងខ្ញុំចែករំលែកតាមវិធីដែលរួមចំណែកដល់ផលប្រយោជន៍សាធារណៈ ដូចជាសុខភាពសាធារណៈ និងការស្រាវជ្រាវ។ យើងខ្ញុំត្រូវបំពេញតាមលក្ខខណ្ឌជាច្រើននៅក្នុងច្បាប់ មុនពេលយើងខ្ញុំអាចចែករំលែកព័ត៌មានរបស់អ្នកសម្រាប់គោលបំណងទាំងនេះបាន។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ៖
www.hhs.gov/ocr/privacy/hipaa/understanding/consumers/index.html

| | |
|---|---|
| **ជំនួយបញ្ហាសុខភាពសាធារណៈ និងសុវត្ថិភាព** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកសម្រាប់ស្ថានភាពជាក់លាក់មួយចំនួនដូចជា៖<br>○ ការបង្ការជំងឺ<br>○ ជួយក្នុងការប្រមូលផលិតផលដែលមានបញ្ហា<br>○ រាយការណ៍ពីប្រតិកម្មមិនល្អចំពោះឱសថ<br>○ រាយការណ៍ពីការរំលោភបំពាន ការធ្វេសប្រហែស ឬអំពើហិង្សាក្នុងគ្រួសារ<br>○ បង្ការ ឬកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព ឬសុវត្ថិភាពរបស់នរណាម្នាក់ |
| **ធ្វើការស្រាវជ្រាវ** | • យើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ការស្រាវជ្រាវសុខភាព។ |
| **អនុវត្តតាមច្បាប់** | • យើងនឹងចែករំលែកព័ត៌មានអំពីអ្នក ប្រសិនបើច្បាប់របស់រដ្ឋ ឬសហព័ន្ធទាមទាររាប់ រួមទាំងចែករំលែក ជាមួយក្រសួងសុខភាព និងសេវាពលរដ្ឋ ប្រសិនបើពួកគេចង់រកមើលថា តើយើងកំពុងអនុវត្តតាមច្បាប់ឯកជនភាពរបស់សហព័ន្ធ ដែរឬទេ ។ |
| **ឆ្លើយតបទៅនឹងសំណើសុំបរិច្ចាគសរីរាង្គនិងជាលិកា ហើយធ្វើការជាមួយអ្នកពិនិត្យផ្នែកវេជ្ជសាស្ត្រ ឬនាយកពិធីបុណ្យសព** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពរបស់អ្នកជាមួយស្ថាប័នលទ្ធកម្មសរីរាង្គ។<br>• យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពជាមួយអ្នកធ្វើកោសល្យវិច័យ អ្នកពិនិត្យផ្នែកវេជ្ជសាស្ត្រ ឬនាយកពិធីបុណ្យសព នៅពេលបុគ្គលនោះស្លាប់។ |
| **ដោះស្រាយសំណងរបស់កម្មករ ការអនុវត្តច្បាប់ និងសំណើរបស់រដ្ឋាភិបាលផ្សេងទៀត** | យើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពអំពីអ្នក៖<br>• សម្រាប់ការទាមទារសំណងរបស់កម្មករ<br>• សម្រាប់គោលបំណងអនុវត្តច្បាប់ ឬជាមួយមន្ត្រីអនុវត្តច្បាប់<br>• ជាមួយភ្នាក់ងារត្រួតពិនិត្យសុខភាពសម្រាប់សកម្មភាពដែលត្រូវបានអនុញ្ញាតដោយច្បាប់<br>• សម្រាប់មុខងារពិសេសរបស់រដ្ឋាភិបាល ដូចជាយោធា សន្តិសុខជាតិ និងសេវាការពារប្រធានាធិបតី |

| | |
|---|---|
| **ឆ្លើយតបទៅនឹងពាក្យបណ្ដឹង និងចំណាត់ការផ្លូវច្បាប់** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពជាការឆ្លើយតបទៅនឹងដីកាបញ្ជារបស់តុលាការ ឬបទបញ្ជារដ្ឋបាល ឬជាការឆ្លើយតបទៅនឹងដីកាកោះហៅ |

## ទំនួលខុសត្រូវរបស់យើងខ្ញុំ

- ច្បាប់តម្រូវឲ្យយើងខ្ញុំ រក្សាឯកជនភាព និងសុវត្ថិភាពនៃព័ត៌មានសុខភាពដែលត្រូវបានការពារពីច្បាប់
- យើងខ្ញុំនឹងប្រាប់អ្នកឱ្យដឹងភ្លាមៗ ប្រសិនបើមានការបំពានអាចកើតឡើង ដែលអាចរួមបញ្ចូលទាំងការបំពានលើឯកជនភាព ឬសុវត្ថិភាពនៃព័ត៌មានរបស់អ្នក
- យើងត្រូវតែអនុវត្តតាមកាតព្វកិច្ច និងការអនុវត្តឯកជនភាពដែលបានពិពណ៌នានៅក្នុងសេចក្ដីជូនដំណឹងនេះ ហើយផ្ដល់ឱ្យអ្នកនូវច្បាប់ចម្លងរបស់វា
- យើងខ្ញុំនឹងមិនប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នក ក្រៅពីអ្វីដែលបានពិពណ៌នានៅទីនេះទេ លុះត្រាតែអ្នកប្រាប់យើងខ្ញុំថា យើងខ្ញុំអាចធ្វើដូច្នេះបានជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអ្នកប្រាប់យើងខ្ញុំថា យើងខ្ញុំអាចធ្វើដូច្នេះបាន អ្នកអាចផ្លាស់ប្ដូរចិត្តនៅពេលក្រោយបាន។ សុមប្រាប់ឱ្យយើងខ្ញុំបានដឹងជាលាយលក្ខណ៍អក្សរ ប្រសិនបើអ្នកផ្លាស់ប្ដូរចិត្ត។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ៖www.hhs.gov/hipaa/for-individuals/notice-privacy-practices/index.html

### របៀបដែលយើងប្រើដើម្បីការពារព័ត៌មានសុខភាពរបស់អ្នក ដែលស្ថិតក្រោមកិច្ចការពារ

គម្រោងសុខភាព (Health Plan) សូមប្ដេជ្ញាចិត្តការពារព័ត៌មាន PHI របស់អ្នក ។ យើងខ្ញុំរក្សាទុកព័ត៌មាន PHI របស់សមាជិកបច្ចុប្បន្ន និងអតីតសមាជិកជាលក្ខណៈឯកជន និងសុវត្ថិភាព តាមតម្រូវការរបស់ច្បាប់ និងស្តង់ដារដែលមានការទទួលស្គាល់ ។ យើងខ្ញុំអនុវត្តតាមនីតិវិធីទាំងនេះ ដើម្បីការពារព័ត៌មាន PHI របស់អ្នក ៖

- យើងប្រើការរបៀបការពារជារូបវន្ត និងអេឡិចត្រូនិច
- យើងតែងបណ្ដុះបណ្ដាលបុគ្គលិករបស់យើងជាប្រចាំ ក្នុងការប្រើប្រាស់ និងការចែករំលែកព័ត៌មាន PHI ឱ្យបានសមស្រប ។
- យើងធានាលើសុវត្ថិភាពការិយាល័យរបស់យើង និងចាក់សោតុធញ្ញវើការ និងទូឯកសាររបស់យើង ជាប់ជានិច្ច ។
- យើងការពារកុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិចរបស់យើង ដោយប្រើពាក្យសម្ងាត់ ហើយអនុញ្ញាតិឲ្យតែបុគ្គលិកណាដែលត្រូវការព័ត៌មាន PHI សម្រាប់ប្រើក្នុងការងាររបស់ពួកគេ ចំពោះសិទ្ធិបើកមើលព័ត៌មាននេះ ។
- ដៃគូអាជីវកម្មរបស់យើង ក៏ត្រូវបានតម្រូវឱ្យការពារភាពឯកជនរបស់ព័ត៌មាន PHI ណាមួយ ដែលយើងបានចែករំលែកជាមួយពួកគេ ហើយពួកគេមិនត្រូវបានអនុញ្ញាតឱ្យផ្ដល់ព័ត៌មាន PHI ដល់អ្នកដទៃឡើយ លើកលែងតែការអនុញ្ញាតដោយច្បាប់ និងដោយសេចក្ដីជូនដំណឹងអំពីការអនុវត្តឯកជនភាពរបស់យើង ។

## ការផ្លាស់ប្តូរលក្ខខណ្ឌនៃសេចក្តីជូនដំណឹងនេះ

យើងខ្ញុំអាចផ្លាស់ប្តូរលក្ខខណ្ឌនៃសេចក្តីជូនដំណឹងនេះ ហើយការផ្លាស់ប្តូរនឹងអនុវត្តចំពោះព័ត៌មានទាំងអស់ដែលយើងខ្ញុំមានអំពីអ្នក។ សេចក្តីជូនដំណឹងថ្មីនឹងមានតាមការស្នើសុំនៅលើគេហទំព័ររបស់យើងខ្ញុំ ហើយយើងខ្ញុំនឹងផ្ញើជូនអ្នកមួយច្បាប់។

## សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាពនេះអនុវត្តចំពោះ៖

Health Plan of San Joaquin/Mountain Valley Health Plan, 7751 South Manthey Road, French Camp, CA 95231

សូមទាក់ទងមកផ្នែកសេវាកម្មអតិថិជនរបស់យើង សម្រាប់សំណួរ ឬកង្វល់ណាមួយទាក់ទងនឹងភាពឯកជនរបស់អ្នកតាមរយៈ piu@hpsj.com ឬ **1-888-936-PLAN (7526) TTY 711** (Medi-Cal) ឬ **1-888-361-PLAN (7526)** (D-SNP) ឬចូលទៅកាន់ www.hpsj-mvhp.org។

## សម្រាប់ព័ត៌មានបន្ថែម

សូមទាក់ទងមកយើងខ្ញុំ ដើម្បីស្នើសុំច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះជាភាសាផ្សេង ឬដើម្បីទទួលបានច្បាប់ចម្លងជាទម្រង់ផ្សេងទៀត ដូចជាអក្សរបោះពុម្ពធំ អក្សរស្ទាប ឬសំឡេង។ ឬអក្សរស្ទាបជាដើម។

កាលបរិច្ឆេទជាធរមាននៃសេចក្តីជូនដំណឹងនេះគឺថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2025។